# ការអនុវត្តន៍ល្អ

## ការដាក់តាំងប៉ាន់គំរូ និងគំនូសព្រាងសំលៀកបំពាក់

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ផលិតផលសំរេច ត្រូវតែបំពេញអោយបាននូវគុណភាព និងលក្ខណៈបច្ចេកទេសម៉ូតសំលៀកបំពាក់ ដែលតំរូវដោយអ្នកទិញ ។ វិធីមួយដើម្បីបំពេញគោលដៅនេះគឺត្រូវតាំងប៉ាន់គំរូផលិតផលសំរេចនៅក្នុងផ្នែកផលិតកម្ម ។ ធ្វើបែបនេះអាចជួយកម្មករអោយមើលឃើញពីរូបរាងផលិតផលសំរេច និងដើម្បីយល់ដឹងពីម៉ូត ទំហំ និងគុណភាពផលិតផលសំរេច ។

### *ការអនុវត្តន៍ល្អសំរាប់ការដាក់តាំងបង្ហាញប៉ាន់គំរូសំលៀកបំពាក់នៅក្នុងផ្នែកដេរ*

ដាក់តាំងទាំងប៉ាន់គំរូសំលៀកបំពាក់របស់រោងចក្រ និងប៉ាន់គំរូរបស់អ្នកទិញ សំរាប់អោយកម្មករមើល ។ ធ្វើបែបនេះអាចជួយកម្មករ និងអ្នកទិញមើលឃើញពីលក្ខណៈផលិតផលសំរេច ( រូបភាពទី១ ) ។



រូបភាពទី១

ដាក់តាំងគំនូសព្រាងសំលៀកបំពាក់នៅក្នុងផ្នែកផលិតកម្ម ។ គំនូសព្រាងត្រូវបង្ហាញគ្រប់ទំហំសំលៀកបំពាក់ទាំងអស់ ។



រូបភាពទី២

**អត្ថប្រយោជន៍:**

- ✓ កាត់បន្ថយហានិភ័យនៃកំហុសឆ្គង
- ✓ កម្មករអាចមើលឃើញច្បាស់ពីលក្ខណៈផលិតផលសំរេច និងជួយបង្កើតអោយមានស្តេរភាពគុណភាព និងផលិតផល
- ✓ ងាយស្រួលសំរាប់កម្មករ និងមេការ ក្នុងការពិនិត្យមើលរង្វាស់សំលៀកបំពាក់
- ✓ ជួយមេការ នៅពេលណែនាំផលិតផលថ្មីដល់កម្មករ

**តាមរបៀបណា:**

- ✓ ប្រើប្រាស់ក្តារខៀន ហើយគូរគំនូរព្រាងសំលៀកបំពាក់នៅលើក្តារខៀន
- ✓ ដាក់បង្ហាញប៉ាន់គំរូសំលៀកបំពាក់របស់រោងចក្រ និងប៉ាន់គំរូរបស់អ្នកទិញនៅក្នុងផ្នែកផលិតកម្ម

**តំលៃ:**

**$**

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់


អង្គការពលកម្មអន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org